ធនាគារជាតិ នៃ កម្ពុជា

លេខ ធ៦.១៣...០២០...០០.៩ ប្រកាសព័ត៌មាន

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

*ថ្ងៃអង្គារ ១៥ កើត ខែបុស្ស ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤*

*រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២០*

# សេចក្តីប្រកាសព័ត៌មាន
# សន្និសីទម៉ាក្រូសេដ្ឋកិច្ចប្រចាំឆ្នាំលើកទី៧ ឆ្នាំ២០២០
# ស្តីពី "ការពិភាក្សាលើម៉ូដែលអភិវឌ្ឍន៍សេដ្ឋកិច្ចកម្ពុជា"

នៅថ្ងៃចន្ទ-អង្គារ ១៤-១៥ កើត ខែបុស្ស ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤ ត្រូវនឹងថ្ងៃទី២៨-២៩ ខែធ្នូ ឆ្នាំ២០២០ ធនាគារជាតិនៃកម្ពុជាបានរៀបចំសន្និសីទម៉ាក្រូសេដ្ឋកិច្ចប្រចាំឆ្នាំលើកទី៧ ឆ្នាំ២០២០ ស្តីពី "ការពិភាក្សាលើម៉ូដែលអភិវឌ្ឍន៍សេដ្ឋកិច្ចកម្ពុជា" តាមរយៈប្រព័ន្ធអនឡាញ ក្រោមអធិបតីភាពរបស់លោកជំទាវ ជា សិរី ឧបការីទេសាភិបាល និងជាអគ្គនាយកបច្ចេកទេសនៃធនាគារជាតិនៃកម្ពុជា។ គោលបំណងនៃសន្និសីទនេះ គឺដើម្បីលើកកម្ពស់ការស្រាវជ្រាវ និងពិភាក្សាជុំវិញម៉ូដែលអភិវឌ្ឍន៍សេដ្ឋកិច្ច ដែលអាចពង្រឹងភាពធន់នៃសេដ្ឋកិច្ចកម្ពុជា និងផ្តល់ធាតុចូលក្នុងការរៀបចំគោលនយោបាយអភិវឌ្ឍន៍សេដ្ឋកិច្ចប្រកបដោយចីរភាពនិងបរិយាបន្ន។

ប្រធានបទចំនួន៨ ត្រូវបានធ្វើបទបង្ហាញនៅក្នុងសន្និសីទនេះ គឺ៖ i/-កំណើនសេដ្ឋកិច្ចមួយខ្ពស់ ប៉ុន្តែនៅមានភាពផុយស្រួយ៖ ការជំរុញការអភិវឌ្ឍសហគ្រាសធុនតូចនិងមធ្យម ដើម្បីពង្រឹងភាពធន់នៃសេដ្ឋកិច្ចកម្ពុជា ii/-ផលប៉ះពាល់ផ្នែកសេដ្ឋកិច្ចនៃជំងឺកូវីដ-១៩ មកលើសហគ្រាសធុនតូចនិងមធ្យមនៅកម្ពុជា៖ ការវិភាគបឋមដោយប្រើប្រាស់ទិន្នន័យផ្លែតហ្វមគណនេយ្យ iii/-វិនិយោគផ្ទាល់បរទេសជាកត្តាជំរុញទំនើបកម្មនិងពិពិធកម្មការនាំចេញរបស់កម្ពុជា iv/-របត់នៃបច្ចេកវិទ្យាឌីជីថលនិងពាណិជ្ជកម្មអន្តរជាតិរបស់កម្ពុជា៖ ការវិភាគដោយផ្អែកលើទិន្នន័យនិងការដាក់ចេញនូវគោលនយោបាយ v/-បញ្ហាប្រឈមនិងកាលានុវត្តភាពនៃការប្រើប្រាស់ឌីជីថលសម្រាប់អ្នកផ្គត់ផ្គង់ធាតុចូលក្នុងវិស័យកសិកម្ម vi/-ការអភិវឌ្ឍសេដ្ឋកិច្ចឌីជីថលនៅកម្ពុជា៖ ទស្សនវិស័យរបស់យុវជន vii/-ការលើកកម្ពស់ការអភិវឌ្ឍកសិកម្មប្រកបដោយចីរភាពតាមរយៈសហករណ៍កសិកម្មនៅកម្ពុជា និង viii/-ឥទ្ធិពលនៃគ្រោះធម្មជាតិនិងហិរញ្ញប្បទាននៅតាមទីជនបទមកលើកសិករ៖ ករណីសិក្សាលើប្រទេសកម្ពុជា និងគោលនយោបាយបរិយាបន្ន។ សន្និសីទនេះមានការអញ្ជើញចូលរួមពីសាធារណជនតាមប្រព័ន្ធអនឡាញសរុប ប្រមាណ ៩០០នាក់។



ប្រអប់សំបុត្រលេខ ២៥, ល្វែងលេខ ៤៨ ផ្លូវលេខ ១០២ កែងនឹងផ្លូវលេខ ១៩ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ , ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ / ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

លទ្ធផលសំខាន់ៗមួយចំនួននៃការស្រាវជ្រាវបានបង្ហាញថា៖

- ការជំរុញការអភិវឌ្ឍវិស័យសហគ្រាសធុនតូចនិងមធ្យមអាចពង្រឹងភាពធន់នៃសេដ្ឋកិច្ចកម្ពុជា
- វិបត្តិជំងឺកូវីដ-១៩ បានប៉ះពាល់ដល់សហគ្រាសធុនតូចនិងមធ្យម ជាពិសេសវិស័យលក់ដុំនិងលក់រាយ ប៉ុន្តែសហគ្រាសដែលប្រើប្រាស់ប្រាក់រៀល ទទួលរងផលប៉ះពាល់តិចជាង ដោយសារអតិថិជនរបស់ពួកគេ ភាគច្រើនគឺជាអតិថិជនក្នុងស្រុក
- កត្តាសំខាន់មួយក្នុងការបង្កើនទំនើបកម្មនិងពិពិធកម្មការនាំចេញរបស់កម្ពុជាគឺការទាក់ទាញការវិនិយោគផ្ទាល់ពីបរទេសទៅក្នុងវិស័យដែលមានតម្លៃបន្ថែមខ្ពស់
- ការបង្កើនការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលអាចជំរុញការនាំចេញរបស់កម្ពុជា
- ការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលក្នុងអាជីវកម្មរបស់អ្នកផ្គត់ផ្គង់ធាតុចូលក្នុងវិស័យកសិកម្មនៅមានកម្រិតនៅឡើយ ដោយសារកង្វះទំនុកចិត្តនិងការយល់ដឹងអំពីអត្ថប្រយោជន៍នៃការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យា
- យុវជនកម្ពុជានៅរាជធានីភ្នំពេញភាគច្រើន ធ្លាប់បានប្រើប្រាស់សេវាកម្មតាមប្រព័ន្ធឌីជីថល និងមានទស្សនៈវិជ្ជមានចំពោះការប្រែក្លាយសេដ្ឋកិច្ចកម្ពុជាទៅជាសេដ្ឋកិច្ចឌីជីថល ប៉ុន្តែមានការព្រួយបារម្ភលើបញ្ហាប្រឈមមួយចំនួន ដូចជា៖ ល្បឿនអ៊ីនធឺណែត តម្លៃអគ្គិសនី និងការលួចទិន្នន័យផ្ទាល់ខ្លួនតាមប្រព័ន្ធបច្ចេកវិទ្យា
- សហករណ៍កសិកម្មបានដើរតួនាទីយ៉ាងសំខាន់ក្នុងការលើកកម្ពស់ជីវភាពកសិករនិងការអភិវឌ្ឍវិស័យកសិកម្មប្រកបដោយចីរភាព និង
- ការលើកកម្ពស់ការប្រើប្រាស់បច្ចេកវិទ្យាហិរញ្ញវត្ថុ និងចំណេះដឹងផ្នែកហិរញ្ញវត្ថុមានសារៈសំខាន់ក្នុងការកាត់បន្ថយភាពក្រីក្រនៅតំបន់ជនបទ។

សន្និសីទនេះប្រព្រឹត្តទៅដោយជោគជ័យ ដោយមានការចែករំលែកនូវបទពិសោធន៍និងលទ្ធផលស្រាវជ្រាវសំខាន់ៗដល់ភាគីពាក់ព័ន្ធទាំងឡាយ ដែលផ្តល់ជាធាតុចូលសម្រាប់ការរៀបចំគោលនយោបាយសេដ្ឋកិច្ច សំដៅរួមចំណែកគាំទ្រការអភិវឌ្ឍសេដ្ឋកិច្ចជាតិប្រកបដោយចីរភាព។

សម្រាប់បទបង្ហាញនិងឯកសារស្រាវជ្រាវក្នុងសន្និសីទនេះ សូមទាញយកតាមរយៈតំណភ្ជាប់៖ https://www.nbc.org.kh/english/publications/research_papers.php។

**ទំនាក់ទំនង ៖**
ផ្នែកទំនាក់ទំនង ធនាគារជាតិនៃកម្ពុជា
ទូរស័ព្ទ ៖ (៨៥៥) ២៣ ៩៨០ ១៩៦
អ៊ីម៉ែល ៖ nbccommunication@nbc.org.kh